# កិច្ចព្រមព្រៀង

# ស្តីពី

# ការជ្រើសរើសពលករ

# រវាង

# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# និង

# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រ
# អារ៉ាប់ប៊ីសាអូឌីត

ធ្វើឡើងនៅទីក្រុងរីយ៉ាដ (អារ៉ាប់ប៊ីសាអូឌីត) 11.02.2016 (ជាភាសាខ្មែរ និងអង់គ្លេស និងអារ៉ាប់,

# កិច្ចព្រមព្រៀង
# ស្តីពី
# ការជ្រើសរើសពលករ
# រវាង
# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និង
# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រអារ៉ាប់ប៊ីសាអូឌីត

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា តំណាងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រអារ៉ាប់ប៊ីសាអូឌីត តំណាងដោយក្រសួងការងារ ដែលនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានហៅថា "ភាគីទាំងពីរ"

**ដោយមានបំណង**ពង្រឹងកិច្ចសហប្រតិបត្តិការស្តីពីការជ្រើសរើសពលករតាមរបៀបមួយដែលផ្តល់អត្ថប្រយោជន៍ដល់ប្រទេសទាំងពីរ រក្សាបានអធិបតេយ្យភាពរបស់ខ្លួន ធានាការគោរពសិទ្ធិរបស់ពលករ និងនិយោជក និង

**ដោយយល់ឃើញ**អំពីសារៈសំខាន់នៃការលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរក្នុងវិស័យនេះ បានព្រមព្រៀងគ្នាដូចតទៅ៖

## ប្រការ ១
## ភាគីទាំងពីរ

ភាគីទាំងពីរនៅក្នុងកិច្ចព្រមព្រៀងនេះគឺ៖
ភាគីទី១៖ ក្រសួងការងារនៃព្រះរាជាណាចក្រអារ៉ាប់ប៊ីសាអូឌីត
ភាគីទី២៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ២
## គោលបំណង

កិច្ចព្រមព្រៀងនេះមានគោលបំណងជ្រើសរើសពលករពីប្រទេសកម្ពុជា ទៅធ្វើការដោយស្របច្បាប់នៅប្រទេសអារ៉ាប់ប៊ីសាអូឌីត ដើម្បីការពារសិទ្ធិរបស់និយោជក និងពលករ និងរៀបចំបទបញ្ញាសម្រាប់គ្រប់គ្រងលើការទំនាក់ទំនងកិច្ចសន្យារវាងពលករ និងនិយោជក។

## ប្រការ ៣
## ចំណុចនៃកិច្ចសហប្រតិបត្តិការ

ភាគីទាំងពីរត្រូវ៖

១. រៀបចំបង្កើតឱ្យមានប្រព័ន្ធនៃការជ្រើសរើស ការដាក់ឱ្យធ្វើការ និងការធ្វើមាតុភូមិនិវត្តន៍ ដែលភាគីទាំងពីរអាចទទួលយកបាន សម្រាប់ពលករកម្ពុជាធ្វើការនៅព្រះរាជាណាចក្រអារ៉ាប់ប៊ីសាអូឌីត ដោយអនុលោមតាមច្បាប់ វិធាន និងបទបញ្ញាដែលអាចអនុវត្តបាន
២. ធានាការជ្រើសរើសពលករ តាមរយៈការិយាល័យជ្រើសរើស ក្រុមហ៊ុនជ្រើសរើស ឬទីភ្នាក់ងារជ្រើសរើសដែលអនុវត្តការជ្រើសរើសដោយត្រឹមត្រូវ និងទទួលបានការអនុញ្ញាតពីរដ្ឋាភិបាលរៀងខ្លួន
៣. កំណត់ ឬខិតខំត្រួតពិនិត្យថ្លៃសេវានៃការជ្រើសរើសនៅក្នុងប្រទេសទាំងពីរ
៤. ធានាថា ការិយាល័យជ្រើសរើស ក្រុមហ៊ុនជ្រើសរើស ឬទីភ្នាក់ងារជ្រើសរើសនៃប្រទេសទាំងពីរ និងនិយោជកមិនត្រូវយកប្រាក់ ឬកាត់ប្រាក់ខែពីពលករសម្រាប់ការជ្រើសរើស និងការដាក់ឱ្យពលករការងារផ្ទះធ្វើការ ឬបង្ខំឱ្យយកប្រាក់ក្នុងប្រភេទណាមួយដែលមិនអនុញ្ញាតឱ្យកាត់ប្រាក់ខែ
៥. ផ្តល់ឱ្យភាគីនៃកិច្ចសន្យានូវសិទ្ធិក្នុងការពឹងពាក់អាជ្ញាធរមានសមត្ថកិច្ចក្នុងពេលមានវិវាទទាក់ទងនឹងកិច្ចសន្យា ដោយអនុលោមតាមច្បាប់ វិធាន និងបទបញ្ញាដែលអាចអនុវត្តបាន
៦. ចាត់វិធានការតាមផ្លូវច្បាប់ទៅលើការិយាល័យជ្រើសរើស ក្រុមហ៊ុនជ្រើសរើស ឬទីភ្នាក់ងារជ្រើសរើស ដែលបានរំលោភច្បាប់ វិធាន និងបទបញ្ញាដែលអាចអនុវត្តបាន និង
៧. ដោះស្រាយរាល់បញ្ហាដែលកើតចេញពីការអនុវត្ត និងការដាក់ឱ្យអនុវត្តបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ។

## ប្រការ ៤
## ការទទួលខុសត្រូវរបស់ភាគីទី១

ភាគីទី១ត្រូវ៖

១. ធានាថា ការជ្រើសរើស ការជូល និងការដាក់ឱ្យពលករធ្វើការដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះត្រូវបានអនុលោមតាមច្បាប់ វិធាន និងបទបញ្ញាដែលពាក់ព័ន្ធ
២. ធានាថា សុខុមាលភាព និងសិទ្ធិរបស់ពលករដែលត្រូវបានប្រើប្រាស់នៅព្រះរាជាណាចក្រអារ៉ាប់ប៊ីសាអូឌីតត្រូវបានលើកកម្ពស់ និងការពារ ដោយអនុលោមតាមច្បាប់ វិធាន និងបទបញ្ញាដែលអាចអនុវត្តបាន
៣. ធានាការអនុវត្តកិច្ចសន្យាការងាររវាងនិយោជក និងពលករ

៤. សម្របសម្រួលដើម្បីនិយោជកបើកគណនីធនាគារក្រោមឈ្មោះពលករ សម្រាប់ដាក់បញ្ចូលប្រាក់ខែរបស់ពលករដូចដែលបានកំណត់នៅក្នុងកិច្ចសន្យាការងារ
៥. ខិតខំបង្កើតយន្តការមួយសម្រាប់ផ្តល់ជំនួយ២៤ម៉ោងដល់ពលករ
៦. ខិតខំសម្របសម្រួលពន្លឿនការដោះស្រាយករណីរំលោភលើកិច្ចសន្យាការងារ និងករណីផ្សេងទៀតដែលត្រូវបានគេដាក់ពាក្យបណ្តឹងទៅអាជ្ញាធរពាក់ព័ន្ធ/តុលាការរបស់ប្រទេសអារ៉ាប់ប៊ីសាអូឌីត
៧. សម្របសម្រួលដល់ការផ្តល់ទិដ្ឋាការចេញសម្រាប់ការធ្វើមាតុភូមិនិវត្តន៍របស់ពលករ នៅពេលបញ្ចប់កិច្ចសន្យាការងារ នៅក្នុងស្ថានភាពបន្ទាន់ ឬតាមការចាំបាច់។

## ប្រការ ៥
## ការទទួលខុសត្រូវរបស់ភាគីទី២

ភាគីទី២ត្រូវ៖

១. ផ្តល់ពលករដែលមានគុណវុឌ្ឍិ និងមានកាយសម្បទាត្រូវតាមតម្រូវការរបស់ភាគីទី១ ស្របតាមការទាមទារជាក់លាក់នៃការងារ
២. ធានាថា ពលករដែលនឹងត្រូវបញ្ជូនទៅធ្វើការមិនមានជាប់ក្នុងកំណត់ត្រាបទល្មើស
៣. ធានាថា ពលករដែលនឹងត្រូវបញ្ជូនទៅធ្វើការបានទទួលការបណ្តុះបណ្តាលអំពីជំនាញសមស្របនៅវិទ្យាស្ថានឯកទេស ឬមជ្ឈមណ្ឌលបណ្តុះបណ្តាល និងបានទទួលការណែនាំតម្រង់ទិសស្តីពីទំនៀមទម្លាប់ ប្រពៃណី របស់ប្រទេសអារ៉ាប់ប៊ីសាអូឌីត និងលក្ខខណ្ឌនៃកិច្ចសន្យាការងារ
៤. តម្រូវឱ្យពលករដែលនឹងត្រូវបញ្ជូនទៅធ្វើការគោរពតាមច្បាប់ សីលធម៌ ក្រមសីលធម៌ និងទំនៀមទម្លាប់របស់ប្រទេសអារ៉ាប់ប៊ីសាអូឌីត ក្នុងខណៈពេលស្នាក់នៅព្រះរាជាណាចក្រអារ៉ាប់ប៊ីសាអូឌីត
៥. ធានាថា ពលករដែលនឹងត្រូវបញ្ជូនទៅធ្វើការបានបញ្ចប់ថិរវេលានៃកិច្ចសន្យារបស់ពួកគេ
៦. ចាត់វិធានការចាំបាច់ក្នុងការសម្របសម្រួលការធ្វើដំណើររបស់ពលករដែលនឹងត្រូវបញ្ជូនទៅធ្វើការនៅក្នុងព្រះរាជាណាចក្រអារ៉ាប់ប៊ីសាអូឌីត ក្នុងរយៈពេលមិនលើសពីមួយខែចាប់ពីកាលបរិច្ឆេទទទួលបានទិដ្ឋាការ និង
៧. បញ្ជូនពលករត្រឡប់មកវិញនៅពេលដែលពលករការងារផ្ទះរំលោភកិច្ចសន្យាការងារ។

## ប្រការ ៦
## គណៈកម្មការបច្ចេកទេសចម្រុះ

គណៈកម្មការបច្ចេកទេសចម្រុះត្រូវបានបង្កើតដោយមានសមាសភាពជាអ្នកតំណាង ដែលដឹកនាំដោយមន្ត្រីជាន់ខ្ពស់នៃភាគីនីមួយៗ។ គណៈកម្មការចម្រុះនេះត្រូវអនុវត្តដូចខាងក្រោម៖

១. ការពិនិត្យឡើងវិញ ការវាយតម្លៃ និងការតាមដានការអនុវត្តកិច្ចព្រមព្រៀងនេះជាកាលិក
២. ដំណើរការកិច្ចប្រជុំពិគ្រោះយោបល់ដោយផ្លាស់វេននៅក្នុងព្រះរាជាណាចក្រកម្ពុជា និង ព្រះរាណាចក្រអារ៉ាប់ប៊ីសាអូឌីត នៅកាលបរិច្ឆេទ និងទីតាំងដែលព្រមព្រៀងដោយភាគីទាំងពីរ និង
៣. ផ្តល់អនុសាសន៍ចាំបាច់ដើម្បីដោះស្រាយវិវាទដែលកើតឡើងពីការអនុវត្ត និងការបកស្រាយបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ឬការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះ តាមការចាំបាច់។

## ប្រការ ៧
## ការដោះស្រាយវិវាទ

រាល់វិវាទដែលកើតឡើងពីការបកស្រាយ ឬអនុវត្តកិច្ចព្រមព្រៀងនេះត្រូវដោះស្រាយដោយភាគីទាំងពីរក្នុងស្មារតីមិត្តភាពតាមផ្លូវការទូត។

## ប្រការ ៨
## ការធ្វើវិសោធនកម្ម

រាល់ការធ្វើវិសោធនកម្ម ឬការពិនិត្យឡើងវិញលើបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត និងត្រូវចូលជាធរមានចាប់ពីកាលបរិច្ឆេទដែលភាគីទាំងពីរបានព្រមព្រៀងគ្នា។

## ប្រការ ៩
## ការចូលជាធរមាន

កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមានចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងជាលាយលក្ខណ៍អក្សរចុងក្រោយដោយភាគីទាំងពីរតាមផ្លូវការទូត ដោយបញ្ជាក់ថា តម្រូវការទាំងឡាយត្រូវបានភាគីទាំងពីរបំពេញរួចហើយ។

## ប្រការ ១០
## សុពលភាព និងចិរវេលា

១. កិច្ចព្រមព្រៀងនេះត្រូវមានសុពលភាពសម្រាប់រយៈពេលប្រាំឆ្នាំ និងត្រូវបានពន្យារដោយស្វ័យប្រវត្តិសម្រាប់រយៈពេលដូចគ្នា ប្រសិនបើគ្មានភាគីណាមួយជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីចេតនានៃការបញ្ចប់កិច្ចព្រមព្រៀងនេះ ក្នុងរយៈពេលពីរខែមុនកាលបរិច្ឆេទផុតសុពលភាពនៃកិច្ចព្រមព្រៀងនេះ។

២. ទោះបីជាកិច្ចព្រមព្រៀងនេះត្រូវបានបញ្ចប់ក៏ដោយ បទប្បញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងនៅតែមានជាធរមានទៅលើការព្រមព្រៀង និងកិច្ចសន្យាទាំងឡាយណាដែលបានធ្វើឡើងក្នុងចិរវេលាដែលកិច្ចព្រមព្រៀងនេះមានសុពលភាព។

កិច្ចព្រមព្រៀងនេះធ្វើឡើងនៅទីក្រុងរីយ៉ាដ 27/04/1437 នៃមហាំម៉ាត់សករាជ ត្រូវនឹង 11/02/2016 នៃគ្រិស្តសករាជ ចំនួនពីរអត្ថបទច្បាប់ដើមក្នុងមួយភាសា ដែលមានភាសាអង់គ្លេស អារ៉ាប់ និងខ្មែរ ដែលអត្ថបទទាំងអស់មានតម្លៃស្មើគ្នាចំពោះមុខច្បាប់ ហើយនៅក្នុងករណីដែលមានការបកស្រាយផ្សេងគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល។

| តំណាងរាជរដ្ឋាភិបាល<br>នៃព្រះរាជាណាចក្រអារ៉ាប់ប៊ីសាអូឌីត | តំណាងរាជរដ្ឋាភិបាល<br>នៃព្រះរាជាណាចក្រកម្ពុជា |
|---|---|
| Muffrig Saad Al Huqbani<br>រដ្ឋមន្ត្រីក្រសួងការងារ | អ៊ិត សំហេង<br>រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |